# វគ្គ អ្នកចម្រៀងមិនទាន់ល្បី

«អាថ៌កំបាំងនៃការច្រៀងគឺ មិនមែនការមានតែសំឡេងដ៏ស្រស់ស្អាតនិងអំណោយដង្ហើម និងនាំអ្នកចម្រៀងម្នាក់ៗឱ្យល្បីឈ្មោះបានទេ! សំឡេងពីរោះៗ ទឹកដមសំនៀងដ៏ល្អឥតខ្ចោះ សាច់ដុំសំឡេងខ្លាំង ណែន និងការដាក់ដង្ហើមចេញពីបេះដូងទៅតាមសាច់រឿង មិនមែនជាទេពកោសល្យកំណើតឡើយ! ទាំងនេះជាអ្វីដែលយើងអាចរៀនបង្ហឹកនិងបង្កើតវាឡើង!»

នាងអានដល់ត្រង់ណេះទម្លាក់ទូរសព្ទចុះ ព្រោះកែវភ្នែកត្រូវបិទបាំងទៅដោយរូបគេ បុរសម្នាក់ដែលនៅជាប់បន្ទប់។ អង្គុលក្ខិណាក្លាយជាអ្នកស្រាវជ្រាវរឿងច្រៀង បច្ចេកទេសប្រើសំឡេង ច្រើនជាងរឿងភ្លេងដែលជាអាជីពរបស់នាង តាំងពីពេលណាមក? គឺតាំងពីពេលដែលនាងជួបគេ នឹងដឹកនាំគេឱ្យធ្វើការហ្វឹកហាត់ជារៀងរាលថ្ងៃ។

ពីបង្អួចម្ខាង សក្ការណ្ណច្រៀងផង ថយចុះឡើងរេរាំទៅតាមទំនុកអត្ថន័យផង ក្រោមការតាមសម្លឹងរបស់ពិនិត្យជួយពន្យល់ចំណុចខ្សោយខ្លាំងពីអង្គ។

នៅក្នុងកូនបន្ទប់ជួលតូចចង្អៀតនេះ នាងបែរជាស្រមៃឃើញរាងកាយខ្ពស់លលៃកំពុងឈរបង្ហើរសំនៀងយ៉ាងសង្ហាលើឆាកធំបំផុតមួយ។

នៅក្រោមពន្លឺភ្លើងLaserក្នុងឆាកស្រមៃនោះ គេគឺជាតារាចម្រៀងឯករបស់កម្ពុជា។

នាងនិយាយមួយៗ៖

«វណ្ណត្រូវចាំថាមនុស្សគ្រប់រូបកើតមកមានកម្រិតសំឡេង និងលក្ខណៈនៃសព្ទសំឡេងខុសៗគ្នា។ សិល្បៈនៃការរៀនច្រៀង និងវិធីកែលម្អសំឡេងច្រៀងផ្ទាល់ខ្លួនរបស់យើងត្រូវរៀនពីរបៀបធ្វើការជាមួយឧបករណ៍ភ្លេង ដើម្បីកែលម្អសំឡេងច្រៀងរបស់យើងឱ្យស៊ីសង្វាក់ជាមួយ ពេលនេះយើងមានតែព្យាណូមួយក៏អូខេ! ក្នុងទិដ្ឋភាពភាពចម្រុះនៃសំឡេង ប្រសិនសំឡេងយើងនៅតែលេចធ្លោលើសពពួកឧបករណ៍នឹងណែនចេញក្រៅ សិល្បៈគេហៅថាតុល្យភាព ការរួមបញ្ចូលល្អឥតខ្ចោះ! ទាំងនេះដែលអ្នកចម្រៀងឯកត្រូវមាន!»

គេងក់ក្បាលហើយច្រៀងបន្តទាំងញញឹមព្រោះកំពុងស្ទុងទៅក្នុងបច្ចេកទេសរបកគំហើញថ្មី។

នាងទះដៃប៉សៗហើយប្រកូកៈ

«តស់សម្រាកបានហើយ! នែ ខ្ញុំធ្វើញ៉ាំស្ងោរត្រីឆ្អើរ ម៉ែផ្ញើមក! បាយជុំគ្នាថ្ងៃនេះណ៎ា»

ជាលើកដំបូងដែលនាងអញ្ជើញវណ្ណមកញ៉ាំបាយជុំគ្នា បន្ទាប់ពីបានស្គាល់គ្នាជាងមួយសប្ដាហ៍មកហើយ។ ខាងប្រុសបញ្ឈប់ចង្វាក់សម្ដែង ដោយប្រែប្រួលទឹកមុខទៅជាក្រហមតិចៗ ប៉ុន្តែអង្គនៅតែញញឹមធ្វើដូចធម្មតា ហាក់ស្រីចង់បញ្ជាក់ប្រាប់ថា អត់មានអ្វីលើសពីនេះទេ។

«គ្រាន់តែ...ខ្ញុំក្រធ្វើបាយញ៉ាំ! យូរៗម្ដងបានធ្វើម្ហូបនៅផ្ទះ គួរតែមានគ្នាញ៉ាំជាមួយ មិនអីុចឹងទេញ៉ាំមិនអស់ដដែល!»

មាណវីចេញមកក្រៅទ្វារដោយលើកម្ហូបខ្លះទៅជូនម្ចាស់ផ្ទះក៏វ៉ាក់អើឃើញគេមកដល់។ ជាមួយទឹកមុខញញឹមសម្លឹងថាសលើដៃនាង តរុណីពន្យល់ប្រាប់គេៈ

«មីងម៉ាប់ ចូលចិត្តញ៉ាំស្ងោរ! ឧស្សាហ៍ឃើញគាត់ធ្វើ ហើយរអ៊ូធ្វើមិនបានឆ្ងាញ់ព្រោះត្រីឆ្អើរមិនល្អ! ហ៎ែ វណ្ណ ចូលបន្ទប់ខ្ញុំមុនបាន ខ្ញុំចុះទៅលឿនទេ!»

អង្គដឹងថា បុរសនេះតាមសម្លឹងនាងពីក្រោយ។ សភាពរបស់គេ នាងចាត់ទុកដូចជាមិត្តជិតស្និទ្ធម្នាក់ ឬថាជាមនុស្សមានទេពកោសល្យតែមានឱកាសតិច ដែលអាចឱ្យនាងសប្បាយចិត្តនៅក្នុងការក្លាយទៅជាផ្នែកមួយនៃអ្នកបង្កឱកាសឱ្យគេ។

អង្គឡើងមកវិញភ្លាមដោយក្ដីសប្បាយរីករាយ នាងបានឃើញគេរង់ចាំនៅមាត់ជណ្ដើរដដែល។

«ឱ្យចូលទៅមុនម៉េចក៏មិនចូល?!»

«ខ្ញុំចង់នៅរង់ចាំអង្គ!»

«អត់ចង់ឱ្យហត់ចាំ!»

«អត់មានអីហត់ទេ! ហើយ....អង្គជាមនុស្សគិតគេណាស់!»

នាងញញឹមហើយនៅស្ងៀមប៉ុន្តែសម្ដីរបស់គេនេះ សាជាថ្មីពិតជាប៉ះចំបេះដូងនាងទៀតហើយ។ បេះដូងជាអ្នកសិល្បៈមួយនេះ ទោះណាមិននិយមឱ្យអ្នកផងបញ្ជើចបញ្ជើបញ្ជោរឬក៏លើកតម្កើងអ្វីហួសហេតុ ប៉ុន្តែបានមានគេយល់និយាយចំចំណុចពិតៗ ជាចំណុចសប្បុរសក៏ជាចំណុចខ្លាំងដែលនាងមានមកពីកំណើត ប្រាកដណាស់អង្គរំភើប។

«សរសើរចំមុខអ៊ីចឹងអត់ដឹងគេអៀនទេ!»

នាងថាហើយដើរហួសផុតទៅ ប៉ុន្តែសក្ការណ្ណដែលដើរតាមពីក្រោយនិយាយបន្ថែមឡើង ៖

«អង្គហ្មែនជាមនុស្សពូកែអៀនអត់ប្រយោជន៍នោះទេ!»

«មានអៀនមានប្រយោជន៍ហើយអៀនអត្ថប្រយោជន៍ទៀត!»

នាងថាឱ្យតបទាំងងាកត្រឡប់មកក្រោយភ្លាមក៏ប្រទះឃើញទឹកមុខខាងប្រុសក្រហមព្រឿងៗឡើងជាលំដាប់។ អង្គដឹងថាដែលអៀនទាំងមានឬគ្មានប្រយោជន៍ កំពុងតែស្តែងឡើងនៅលើផ្ទៃមុខបុរសម្នាក់នេះ ដូចគេកំពុងមានសម្ពាធព្រោះរឿងផ្លូវចិត្ត។ ជាអ្នកនិពន្ធដែលបានស្រាវជ្រាវច្រើន នាងដឹងថា មនុស្សយើងអាចមានការភាន់ច្រឡំលើប្រតិកម្មរបស់ខ្លួនឯងផងកុំថាឡើយរបស់អ្នកដទៃដូច្នេះ អង្គមិនព្រមទទួលថាវណ្ណចាប់អារម្មណ៍លើនាងទេ។ ទោះយ៉ាងណា អង្គមិនអាចយកអារម្មណ៍នេះចេញពីការគិតរបស់ខ្លួនជាសម្ងាត់នោះភ្លាមៗដដែល អ៊ីចឹងមានតែខំបន្លប់ទៅរករឿងផ្សេង

ស្រីហុចចានពីរទៅឱ្យសក្ការណ្ណ និងស្លាបព្រាដួសបាយទៅផង។

«ដួសបាយទៅអ៊ីចឹង!»

ទ្វារមិនបានបិទទេ។ ពួកគេចង់បើកចំហអ្វីៗនៅក្នុងបន្ទប់នេះ តាមរយៈបេះដូងបើកចំហរបស់ពួកគេ។

នៅចំកណ្ដាលបន្ទប់តូចក្រៅពីព្យាណូ ហើយនឹងគ្រែគេងមួយដែលគ្របភួយជិត មានការសម្អាតស្អាតតុបតែងសមរម្យ សក្ការណ្ណបានឃើញកូនតុតូចដែលមានកៅអីពីរនៅចំកណ្ដាល ។

នាងពិតជាមានការត្រៀមរៀបចំវាឡើងមកជាពិសេស ដើម្បីគ្រាន់តែនឹងញ៉ាំបាយជាមួយគ្នានៅក្បែរមាត់បង្អួច ក៏ជាបង្អួចដែលគេតែងតែផ្លាស់មកនិយាយលេងជាមួយនាង ឬក៏ស្ដាប់នាងប្រាប់អំពីទ្រឹស្ដីនៃបទភ្លេងនិងការប្រើប្រាស់សំឡេងឱ្យបានត្រឹមត្រូវ។

«ចេះធ្វើម្ហូបច្រើនមុខណាស់អង្គ!»

ប្រុសវាចាតិចៗជាមួយកែវភ្នែកបង្ហាញថាពេញចិត្តខ្លាំង។

«ថ្ងៃនេះមិនដឹងយ៉ាងម៉េចដែរ ធ្វើបានច្រើនហើយលឿនទៀត! ប្រហែលមកពីសប្បាយចិត្តទេហើយមើលទៅ!» នាងតប។

«ហេតុអីទៅ?!»

«ថ្ងៃកំណើតរបស់ខ្ញុំ!»

វណ្ណបានបើកភ្នែកធំៗ។

«ខ្ញុំអត់មានអំណោយទេមិនសមសោះ! Happy Birthday!»

«វត្តមានវណ្ណនេះជាអំណោយហើយ!»

ប្រុសព្នកាលណាកាន់តែក្រហមមុខ ញញឹមស្រស់សម្លឹងមុខនាង។

«មែន?!»

នារីងក់ក្បាលតប៖

«ឆ្នាំមុនៗ ញ៉ាំបាយចត់ម្នាក់ឯង!»

គេងក់ក្បាលតិចៗ ព្រោះគេងាយយល់ណាស់អារម្មណ៍នេះ។ អារម្មណ៍ឯកោ នៃអ្នកដែលមកនៅភ្នំពេញម្នាក់ឯងដោយមិនទាន់ជោគជ័យ។ ប្រសិនយើងជាបុគ្គលជោគជ័យ មិនខ្វះនំបញ្ជូនមកដល់ផ្ទះយើងនោះទេ មិនថាអ្នកនោះជាអ្នកណា គេតែងតែចង់ពាក់ព័ន្ធនឹងថ្ងៃល្អៗរបស់យើង តែជីវិតមនុស្សដែលគ្មានអ្វីសោះ ឋានៈ លុយកាក់ ការមានអ្នកណាម្នាក់មកនៅក្បែរនាថ្ងៃខួបបែបនេះ ពិតជាពិសេសពេកហើយ។

ឃើញខាងប្រុសរិះគិតស្ងប់ស្ងៀមទាំងទឹកមុខស្រទោស្រទន់ អង្គវាចាបន្ត៖

«អំណោយខ្លះ យើងមិនត្រូវការលុយទេ ហើយខ្ញុំក៏ដឹងថាវណ្ណគ្មានលុយដែរ!»

ថាចប់ នាងសើចកក្អឹកបណ្ដាលឱ្យខាងប្រុសចំហមាត់នៅចំពោះមុខសម្រស់នៃភាពស្មោះត្រង់របស់មនុស្សស្រីម្នាក់នេះ។

នារីតូចដែលមានទាំងភាពក្លាហាន មានជំនាញ ចំណេះដឹង អត្តចរិតល្អ រូបសម្រស់ហើយមានសមានចិត្តទៀតទៅរកឯណាបាន?

គេសម្លឹងអង្គលក្ខិណាភ្លឹកស្មារតីមុនពេលរីកស្នាមញញឹមលំដាប់លំដោយបន្តពីក្រោយនាង។

«ជូនពរឱ្យគម្រោងការងារនៅ G-Brothers បានសម្រេច!»

ថាប្រយោគជូនពរចប់ ប្រុសទម្លាក់មុខមកក្រៀមក្រំប៉ុន្តែគេប្រឹងបំភ្លៃមកវិញ។ អង្គដឹងភ្លាមថា គេនឹកឃើញដល់ការទន្ទឹងរង់ចាំដំណឹង មិនឃើញមានអ្នកទាក់ទងមកសោះជាងមួយសប្ដាហ៍មកហើយ បានជាជ្រុលនិយាយដល់ក្រុមហ៊ុនមួយនោះកាលណាវណ្ណចេះតែកើតឡើងនូវរូបភាពអស់សង្ឃឹម។

យល់ការណ៍ហើយមាណវីយើងបន្តញញឹមនិងផ្ដើមចាប់ម្ហូបឱ្យទៅបុរសនេះ។

«ឈប់គិតពីរឿងមិនសប្បាយចិត្តណ៎ា នេះជាច្បាប់សម្រាប់បើកទ្វារទទួលយករឿងសប្បាយចិត្ត!»

«ច្បាប់អ្នកណាចែង?» គេសួរទាំងផ្ដើមហូប។

«ខ្ញុំចែងខ្លួនឯង!»

«ដឹងតាស៎»

«អ៊ោ! បើមិនឈប់Sad ម៉េចនឹងមានកន្លែងទទួល Happy ?»

«ទទួលបញ្ជាមេ!»

ថាហើយវណ្ណបន្តញ៉ាំអាហារហាក់សប្បាយចិត្តជាងមុនឡើងពេលបានឮនាងពន្យល់។ ចង់ឱ្យគេបន្ថែមភាពធូរស្រាលមកក្នុងជីវិតនិងអាលបំពក់បានសុទិដ្ឋិនិយមរឹងមាំឡើងៗ ស្រីក៏បង្អើបប្រាប់ទៀត៖

«ប្រាប់រឿងមួយ! ខ្ញុំបានទាក់ទងទៅបងពិស្ដារប្រាប់អំពីរឿងវណ្ណ! ខ្ញុំប្រាប់ថា មានបេក្ខជនម្នាក់ដែលច្រៀងក្រោយគេនៅថ្ងៃគាត់ណាត់ខ្ញុំទៅ G-brothers នោះ! គាត់ចាប់អារម្មណ៍ហើយប្រាប់មកវិញថា អូខេចាំគាត់ឆែក!»

វណ្ណហាក់ចាប់អារម្មណ៍ប្រយោគចុងក្រោយនេះខ្លាំងដល់ថ្នាក់ទម្លាក់សមស្លាបព្រាចុះសន្សឹមៗ។ ភ្នែករបស់គេមិនដឹងថាគេសប្បាយរីករាយដោយសារឃើញនាងប្រឹងប្រែងជួយ ឬមួយក៏គេស្រមៃឃើញឥទ្ធិពលនៃបុរសផលិតករវ័យក្មេងដ៏មានកេរ្តិ៍ឈ្មោះនោះឡើយ។

«និយាយយូរនៅ?!»

«អត់ទេ! ទើបតែម្សិលមិញ! បងពិស្ដាជាមនុស្សធំកាន់ការងារច្រើន គាត់រវល់ណាស់ប៉ុន្តែគាត់ថាឆែក គឺប្រាកដជាគាត់នឹងឆែក! ខ្ញុំជឿថាអ៊ីចឹង! គិតអ៊ីចឹងអត់វណ្ណ?»

វណ្ណញញឹម តែមិនឆ្លើយ។ គេទុកឱ្យពន្លឺភ្នែកដែលចិញ្ចាចសម្ដែងអំណរនិងការដឹងគុណការស្រឡាញ់បង្ហាញមនោរម្មណ៍មកជំនួសឱ្យបណ្ដាពាក្យពេចន៍រាប់រយ។ វាជាកម្រងពាក្យពេចន៍មិនចេះរីងស្ងួតព្រោះតែឥទ្ធិពលបេះដូងកំពុងលោតកក់ក្ដៅ សំខាន់និយាយមិនចេញ។ ស្នេហាដំបូង ច្រើនផ្ដើមឡើងមកពីការទទួលអារម្មណ៍ថាមានមនោសញ្ចេតនាពិសេសណាមួយចំពោះអ្នកដទៃកំពុងបង្កជាសារធាតុទាក់ទាញយកការផ្ដោតអារម្មណ៍ក្រាស់ឡើងៗ ធូន់ឡើងនៅក្នុងខួរក្បាលយើង។

«ម៉េចភ្លឹក?» នាងសួរពេលគេសម្លឹងនាងផ្ទាំង។

«ខ្ញុំចូលចិត្តអង្គ»

«ហេតុអីទៅ?»

«ខ្ញុំមិនដឹងទេ!»

«ព្រោះរឿងបងពិស្ដា?»

«អត់ទេ! ដែលអង្គល្អជាមួយខ្ញុំនោះជាហេតុផលដំបូងពេលចាប់ផ្ដើមគិត ប៉ុន្តែការចូលចិត្តកាន់តែជ្រៅឡើង គឺនៅពេលស្គាល់អង្គ!»

«ពូកែគិតថាស្គាល់មនុស្សច្បាស់ម៉េះ?»

«មនុស្សដែលមានសុទិដ្ឋិនិយម ពូកែនិយាយ ពូកែធ្វើការ និងពិបាករកមកដូច!»

«និយាយដូចកវីនិពន្ធ!»

«ប្រហែលជាមកពីស្នាក់នៅជិតបន្ទប់កវីនិពន្ធដឹង?!»

«ខ្ញុំមិនល្អថ្នាក់ហ្នឹងទេ! ចង់និយាយអ៊ីចឹង!»

«ការដែលនៅសុខៗយើងគិតថាមានមនុស្សណាម្នាក់ដែលពិសេសហើយយើងផ្ដោតលើគុណសម្បត្តិ វិជ្ជមានរបស់គេមានអីខុស? អាចជាអារម្មណ៍នៃការចងចាំល្អៗច្រើនពេកហើយបន្តជារហូតមកដល់ថ្នាក់ខ្ញុំមានសុបិនពីថ្ងៃអនាគតមួយដែលពិបាកនឹងគ្មានមនុស្សម្នាក់នោះ!»

នាងបន្ថយល្បឿនញ៉ាំ រហូតដល់ឈប់ទាំងស្រុងពេលឮប្រយោគនេះ។ ខាងប្រុសកំពុងឈានហួសល្បឿនដល់សារភាពស្នេហ៍?

នាងងើបមុខឡើងមកសន្សឹមៗនិងសម្លឹងទៅរកផ្ទៃមុខនាយ។ កែវភ្នែកមនុស្សម្នាក់ដែលធ្លាប់តែអៀនប្រៀន ពេលនេះផ្ដោតសម្លឹងមកនាងវិញដែរ។ វណ្ណាមិនបានគេចវេះពីពាក្យសម្ដីរបស់គេទេ។ គេនៅជំអក់ក្នុងពន្លឺភ្នែកនាង ជាការបញ្ជាក់ន័យឱ្យប្រយោគរបស់ខ្លួន។

ទូរសព្ទរបស់នាងរោទ៍....

នេះជាឱកាសបន្ធូរភាពតឹងតែង។ នាងលើកដៃទទួលភ្លាមៈ

«ខ្យល់អីបក់ឯងទូរសព្ទមកខ្ញុំរតនៈ?»

សំឡេងពីចុងម្ខាងតបវិញ ៖

«អង្គ ឯងវ័ណ្ណកហើយវើយ! យើងត្រូវការអ្នកចម្រៀងម្នាក់ អ្នកចម្រៀងពិសេសរបស់យើង វាលេងយើងមួយក្បាច់! លេងឡើងធ្ងន់ដោយសារខឹងយើងរឿងឃឹតលុយកក់! ឥឡូវនេះទៅប្រទេសក្រៅបាត់!»

«រតនៈ!!! ពីពេលណាដែលឯងយល់សប្ដិឃើញថាយើងនេះជា Talent Manager អ្ហះ? គ្នាទៅមានអ្នកចម្រៀងឯណាមកឱ្យឯងនោះ?»

និយាយត្រង់ណេះស្រាប់តែអង្គងើបមុខវាក់អើនឹងវណ្ណ។ នាងស្រាប់តែនឹកឃើញភ្លាមៈ

«ឈប់ៗៗៗ ចង់បានអ្នកចម្រៀងប្រុសឬស្រី ហើយកម្រិតណា?!»

«ឱនាង! ឯងដឹងស្រាប់ហើយ! យើងទទួលយកតែ Event លំដាប់នៅផ្ទះអ្នកធំ មហាសេដ្ឋី! អ្នកចម្រៀងប្រុសនាង! យកអ្នកល្បីឈ្មោះ ហោចណាស់ធ្លាប់ចេញអាល់ប៊ុមថ្មី ឬក៏ល្បីឈ្មោះនៅលើយូធូបដែរ!»

«ចុះបើអត់ល្បីប៉ុន្តែច្រៀងដូចតួល្បីយកដែរទេ?!»

«ថាម៉េច?!»

«អូខេ និយាយអ៊ីចេះណ៎ាពួកម៉ាក! រូបរាងស្អាតដូចជាតារាកម្រិតតំបន់ មិនមានកម្រិតប្រទេស ស្នាមញញឹមស្រស់ច្រៀងបានក្រអួនល្អ ទំនុកច្រៀងនិងទំនុកភ្លេងជាងមួយពាន់បទគេច្រៀងបានត្រូវទាំងអស់ សឹងតែគ្រប់អ្នកចម្រៀងល្បីៗមកពីមុនគឺអាចច្រៀងតាមបាន!»

«អូយ ហើយពិសេសម្ល៉េះ? តែសួរសិន មានបទចម្រៀងខ្លួនឯងទេ?!»

«ប្រាប់ហើយថាមិនទាន់ល្បី! មានន័យថាបន្តិចទៀតនឹងល្បីហើយ!»

«អូខេ! ផ្ញើរូបថតមកខ្ញុំតិចមក នឹងអាត់សំឡេងមួយផង!»

«បាន!»

នារីដាក់ទូរសព្ទចុះស្របពេលដែលសក្ការវណ្ណបានធ្វើមុខស្លេកស្លាំងសម្លឹងមុខនាង។

«ម្នាក់មិញមិនមែនអង្គកំពុងណែនាំខ្ញុំទេដឹង?!»

«ចុះម៉េចបានភ័យស្លេក!»

«អត់ភ័យទេ!»

«ប៉ុន្តែមុខរបស់សក្តាវណ្ណកុហក! មិនដូចសម្តីអះអាងនេះទេ!»

គេលើកដៃស្ទាបមុខជាមួយម្រាមដៃធំខណៈនាងនិយាយទៀតៈ

«អូខេ ឈប់ហើយញ៉ាំញ៉ាំស្តៅ ញ៉ាំស៊ុបទៅ!»

«ហេតុអី?!»

«បើស្អែកគេហៅទៅសាកសំឡេងស្អកគិតម៉េច?!»

«ម៉េចដឹងថាគេឱ្យខ្ញុំសាក?!»

«គេផ្ញើសារមកវិញបង្ហាញទីតាំងហើយហ្នឹង! គឺអូខេបានសាកហើយ! អូយ ព្រះទម្លាក់ឱកាសពីលើមេឃមកហើយ ចាប់ឱ្យជាប់វណ្ណ!»

នាងសប្បាយចិត្តយ៉ាងនេះ នាយកាន់តែបង្ហាញភាពស្លេកស្លាំង។

«ប៉ុណ្ណឹងស្លេកដែរ?»

«អម្បាញ់មិញនេះអង្គុយអួតអំពីខ្ញុំពេកហើយ!»

«ខ្ញុំមានថាអីលើសពីការពិតខ្លះ?!»

«គឺរឿងរូបសម្រស់ ហោះថ្នាក់តំបន់អីហ្នឹង?!»

ស្រីអង្គសើចចិញ្ចាចបញ្ចេញធ្មេញលើក្រោមស្រស់ប្រផូរធ្វើឱ្យខាងប្រុសដែលនៅទីទើរបង្អែបង្អង់ដោយទឹកមុខអៀនប្រៀនញញឹមញញែម មិនជឿទុកចិត្តខ្លួនឯងផងមោទនភាពផងលាយលំគ្នានៅចំពោះមុខស្រីស្អាត។

ពេញមួយល្ងាចដែលនៅសល់ ពួកគេបានហ្វឹកហាត់នូវបណ្តាបទចម្រៀងល្បីៗមួយចំនួនដើម្បីជាការបង្ហាញខ្លួននៅថ្ងៃស្អែកសាកសំឡេងចំពោះមុខបុរសម្ចាស់ Event ដ៏ល្បីឈ្មោះនៅក្នុងចំណោមអ្នកមានទ្រព្យសម្បត្តិគឺលោករតនៈ។